ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ : ៥៤៩
ចុះថ្ងៃទី ២០_១០_២០០៨
សាលដីកា
លេខ : ១១២ "ខ"
ចុះថ្ងៃទី ២២_១០_២០១០

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

**********

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៣_១០_២០១០ ដោយមានសមាសភាពដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៥៤៩ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៨ ដែលមាន:

១- ជនជាប់ចោទឈ្មោះ [redacted]បុខា ភេទប្រុស អាយុ ៦៥ឆ្នាំ ជាតិខ្មែរ មុខរបរពាណិជ្ជករ កើតនៅភូមិទូកមាស ឃុំទូកមាស ស្រុកទូកមាស ខេត្តកំពត ទីលំនៅមុនចា[redacted]ង្កាត់ទឹកល្អក់ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] មានកូន ០៤នាក់ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី ២៥-១០-២០០៦ ឃុំខ្លួនថ្ងៃទី ២៧-១០-២០០៦ នៅពន្ធនាគារ ម១។

មានមេធាវី លោក [redacted]សារឿន។

២- ជនជាប់ចោទឈ្មោះ [redacted]ចាន់នី ភេទស្រី អាយុ ៤៣ឆ្នាំ ជាតិខ្មែរ មុខរបរលក់អង្ករ កើតនៅភូមិលក ឃុំឬស្សី ស្រុកកំពង់ត្រាច ខេត្តកំពត ទីលំនៅសព្វ[redacted] សង្កាត់ទឹកល្អក់ ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្តីឈ្មោះ [redacted] មានកូន ០៤នាក់ ទោសពីមុនគ្មាន បច្ចុប្បន្នគេចខ្លួន។

<u>**ជាប់ចោទពីបទ:**</u> រំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០១ ខែតុលា ឆ្នាំ២០០៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ច័ន្ទតារា ភេទប្រុស អាយុ ៣៤ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] សុខណា អាយុ ៣១ឆ្នាំ មុខរបរលក់អង្ករ ទីលំនៅសព្វថ្ងៃផ្ទះលេខ ៧អា ផ្លូវលេខ ២៩ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

- តាមពាក្យបណ្តឹងឧទ្ធរណ៍លេខ ១៣១ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០០៧ របស់ឈ្មោះ [redacted] សុខា ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៥៥ (ខ) ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៧ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

388

ដំណើររឿងមានដូចតទៅ:

កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៥ ឈ្មោះ[redacted]ច័ន្ទតារា ប្រពន្ធឈ្មោះ[redacted] សុខណា បានធ្វើកិច្ចសន្យាជាមួយឈ្មោះ[redacted] សុខា ប្រពន្ធឈ្មោះ[redacted] ចាន់នី ដោយឈ្មោះ[redacted] ច័ន្ទតារា ប្រពន្ធឈ្មោះ[redacted]សុខណា បានប្រគល់ប្រាក់ទៅឱ្យឈ្មោះ[redacted] សុខា ប្រពន្ធឈ្មោះ [redacted] ចាន់នី ចំនួន ៥៨០០ដុល្លារអាមេរិក ដើម្បីចូលហ៊ុនក្នុងការលក់អង្ករ ។ ក្នុងការរកស៊ីនេះឈ្មោះ[redacted]សុខា ប្រពន្ធឈ្មោះ[redacted] ចាន់នី បានសន្យាថា ក្នុងមួយខែប្រគល់ប្រាក់ចំណេញ ពីរលើក មួយលើក ៦០០ ដុល្លារ ចំពោះប្រាក់ដើម ៥៨០០ដុល្លារ ។ លុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៦ បានធ្វើកិច្ចសន្យារវាងឈ្មោះ [redacted] ច័ន្ទតារា ប្រពន្ធឈ្មោះ [redacted] សុខណា (ជាភាគី "ខ") បានប្រគល់ប្រាក់ទៅឱ្យឈ្មោះ[redacted] សុខា ប្រពន្ធឈ្មោះ[redacted] ចាន់នី (ជាភាគី "ក") ចំនួន ១១០០០ដុល្លារ ដើម្បីចូលហ៊ុនក្នុងការលក់អង្ករ ក្នុងការរកស៊ីនេះឈ្មោះ [redacted] សុខា ប្រពន្ធឈ្មោះ[redacted] ចាន់នី បានសន្យាថា ក្នុងមួយខែ១ គាត់ប្រគល់ប្រាក់ចំណេញពីរលើក ក្នុងមួយលើក១ចំនួន ១២០០ដុល្លារ ចំពោះប្រាក់ដើម ១១០០០ដុល្លារ ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៥៥ (ខ) ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៧ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ:

១- ផ្ដន្ទាទោសលើឈ្មោះ[redacted]សុខា ភេទប្រុស អាយុ ៦៤ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៤ឆ្នាំ (បួនឆ្នាំ) គិតពីថ្ងៃទទួលទោសនៃសាលក្រមមុន ពីបទ រំលោភលើសេចក្ដីទុកចិត្ត ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០១ ខែតុលា ឆ្នាំ២០០៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២- ផ្ដន្ទាទោសលើឈ្មោះ[redacted]ចាន់នី ភេទស្រី អាយុ ៤៣ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំ (ប្រាំឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនបាន និងយកមកឃុំនៅពន្ធនាគារ ម២ នៃក្រសួងមហាផ្ទៃ ពីបទ រំលោភលើសេចក្ដីទុកចិត្ត ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០១ ខែតុលា ឆ្នាំ២០០៦ បទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣- បង្គាប់ឱ្យឈ្មោះ [redacted]សុខា ឈ្មោះ [redacted]ចាន់នី រួមគ្នាសងសំណងខូចខាតចំនួន ៤៩.៨០០ដុល្លារអាមេរិក (បួនម៉ឺនប្រាំបួនពាន់ប្រាំបីរយដុល្លារអាមេរិក) ទៅឱ្យឈ្មោះ [redacted]ច័ន្ទតារា ជាដើមបណ្ដឹងរដ្ឋប្បវេណី គិតពីសាលក្រមចូលជាស្ថាពរ ។ ក្នុងករណីទណ្ឌិតមិនមានប្រាក់ធនទណ្ឌសងគ្រប់ចំនួនទេ ត្រូវរឹបអូសទ្រព្យសម្បត្តិអ្នកទាំងពីរនេះ លក់ឡាយឡុងដើម្បីសងប្រាក់ធនទណ្ឌគ្រប់ចំនួន បើរឹងរូសត្រូវដាក់គុកបង្ខំរូបកាយ តាមមាត្រា៧៧នៃច្បាប់ស្ដីពីការដាក់គុកបង្ខំរូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៤- សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted] សុខា កំបាំងមុខជនជាប់ចោទឈ្មោះ[redacted]ចាន់នី ចំពោះមុខដើមបណ្ដឹង សម្រេចបើកផ្លូវប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញ ពាក្យបណ្ដឹងឧទ្ធរណ៍លេខ ១៣១ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០០៧ របស់ឈ្មោះ[redacted]សុខា ជាជនជាប់ចោទ ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៥៥ (ខ) ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៧ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍ ។



Scanned with CamScanner

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។

នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ប្រធានក្រុមប្រឹក្សាអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ច័ន្ទតារា បានឆ្លើយនៅសាលាដំបូងរាជធានីភ្នំពេញ។

ជនជាប់ចោទឈ្មោះ [redacted] សុខា ឆ្លើយថាៈ ខ្លួនមិនសុខចិត្តដោយតុលាការថ្នាក់ក្រោមកាត់ទោសខ្លួនធ្ងន់ពេក ខ្លួនត្រូវបានគេឃុំខ្លួននៅថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៦ ដូច្នេះ ខ្លួនសុំឱ្យសាលាឧទ្ធរណ៍មេត្តាបន្ធូរបន្ថយទោសឱ្យខ្លួនផង។

សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានពិនិត្យសំណុំរឿង ក្រោយពីបានស្តាប់របាយការណ៍ខាងលើ ក្នុងសំណុំរឿងនេះមានការកត់សម្គាល់ ២ចំណុច ទី ១ មានកិច្ចសន្យារកស៊ី ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០០៥ ដែលវិវាទនេះមិនមែនរឿងព្រហ្មទណ្ឌទេ ទី ២ តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយថា ជនជាប់ចោទមិនបានបង់ប្រាក់ទ្បេងទាត់ឱ្យខ្លួនទេ ដែលនេះជាកាតព្វកិច្ច ដែលមិនព្រមបង់ប្រាក់តាមមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល គប្បីក្រុមប្រឹក្សាពិចារណាឡើងវិញ ព្រោះរឿងនេះ មិនមែនជាវិវាទព្រហ្មទណ្ឌ ដូច្នេះ ក្នុងនាមខ្លួនជាតំណាងមហាអយ្យការយល់ឃើញថា ចំណុចទី ២ រឿងនេះជាបទល្មើស ព្រហ្មទណ្ឌ ហើយការចោទប្រកាន់ និងសម្រេចត្រឹមត្រូវ ហើយដោយជនជាប់ចោទមានគំនិតទុច្ចរិតគិតទុកជាមុន វាមិន មែនជាវិវាទកិច្ចសន្យាទេ នេះជាចំណាររបស់អគ្គព្រះរាជអាជ្ញាទេដែលសន្និដ្ឋានតម្កល់សាលក្រម តែក្នុងនាមខ្លួនជាតំណាង មហាអយ្យការជាវិវាទកិច្ចសន្យា ដូច្នេះ សូមក្រុមប្រឹក្សាពិចារណា។

សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ រឿងនេះជាវិវាទកិច្ចសន្យាដែលទាក់ទងការចូល ហ៊ុនគ្នា ដោយនៅក្នុងកិច្ចសន្យាមិនបានកំណត់ពីការចំណេញ ឬការកិបកេងទេ ដូច្នេះ ខ្លួនសុំឱ្យក្រុមប្រឹក្សាមេត្តាបង្វិល សំណុំរឿងនេះទៅជារឿងរដ្ឋប្បវេណីវិញ។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់។

សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថាៈ

១- បណ្តឹងឧទ្ធរណ៍លេខ ១៣១ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០០៧ របស់ឈ្មោះ [redacted] សុខា ជាជនជាប់ចោទ ធ្វើឡើងនៅក្នុងកំណត់ច្បាប់។

២- តាមចម្លើយជនជាប់ចោទថា ខ្លួន និងប្រពន្ធឈ្មោះ [redacted] ចាន់នី កាលពីថ្ងៃខែមិនចាំ បានទៅផ្ទះជនរងគ្រោះ ហើយបបួលជនរងគ្រោះរកស៊ីអង្ករមែន។ ពេលនោះជនរងគ្រោះក៏ព្រម ហើយបានប្រគល់ប្រាក់មកឱ្យ [redacted] ចាន់នី



Scanned with CamScanner

ជាប្រពន្ធខ្លួនចំនួន ១៧០០០ ដុល្លារអាមេរិក ដោយមានធ្វើកិច្ចសន្យាជាសម្គាល់ ហើយខ្លួនបានផ្តិតស្នាមមេដៃជាសាក្សី តែខ្លួនមិនដឹងថា [redacted] ចាន់ទី យកទៅចាត់ចែងរបៀបណាឡើយ ហើយសព្វថ្ងៃនាង [redacted] ចាន់ទី បានរត់គេចខ្លួនបាត់ហើយ កាលពីថ្ងៃទី ០១-១០-២០០៦ ។

៣- តាមចម្លើយជនរងគ្រោះថា ជនជាប់ចោទបានមកបបួលល្បួងលោងលោមខ្លួនឱ្យរកស៊ីលក់អង្ករជាមួយ ដោយជនជាប់ចោទ ប្តី-ប្រពន្ធ ជាអ្នកទិញលក់ ជួលឃ្លាំង និងប្រមូលប្រាក់ដោយផ្ទាល់ ហើយបានសន្យាតាមកិច្ចសន្យា ចុះថ្ងៃទី ៣១-១០-២០០៥ ថា ក្នុងមួយខែ ប្រគល់ប្រាក់ចំណេញឱ្យខ្លួនពីរលើក ក្នុងមួយលើក ៦០០ដុល្លារអាមេរិក តាមកិច្ចសន្យា ចុះថ្ងៃទី ០៣-០២-២០០៦ ថា ឱ្យពីរលើក ក្នុងមួយលើក ១២០០ដុល្លារអាមេរិក ។ ជនជាប់ចោទបានយកប្រាក់ពីខ្លួនដោយមានលិខិតស្នាមនិងគ្មានលិខិតស្នាម សរុប ៤៩០០០ ដុល្លារអាមេរិក ។

៤- មានពិរុទ្ធលើជនជាប់ចោទ ពីបទ រំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០១ ខែតុលា ឆ្នាំ២០០៦ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៥- សាលក្រមព្រហ្មទណ្ឌលេខ ៥៥ (ខ) ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៧ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចត្រឹមត្រូវ គួរតម្កល់ទុកជាបានការ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ១៣១ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០០៧ របស់ឈ្មោះ [redacted] សុខា ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៥៥ (ខ) ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៧ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល តែលុបវិធានអនុវត្តចេញ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០ និងប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០ ចំពោះមុខមេធាវីការពារជនជាប់ចោទ និងជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួល បន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា [redacted] |

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ... ខែ ០... ឆ្នាំ២០១១

ក្រឡាបញ្ជី

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]